

## ជំពូកទី២

# កុមារមិនអាចស្តាប់ឮល្អ ត្រូវការជួយតាំងពីអាយុនៅតិច

នៅក្នុងឆ្នាំដំបូងនៃជីវិតរបស់កុមារគ្រប់រូប រួមបញ្ចូលទាំងកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អ អាចរៀនបំណិនផ្សេងៗ ជាច្រើនបានឆាប់រហ័ស ហើយងាយស្រួលជាងពេលណាៗទាំងអស់ក្នុងជីវិតរបស់ពួកគេ។ ការអភិវឌ្ឍកាយសម្បទារបស់កុមារងាយមើលឃើញណាស់ ដំបូងពួកគេចេះវារ បន្ទាប់មកចេះដើរ និងចេះរត់។




កុមារក៏បានចាប់ផ្តើមអភិវឌ្ឍគំនិតបញ្ញាយ៉ាងឆាប់រហ័ស ទន្ទឹមពេលកើតភ្លាមអញ្ចឹងដែរ។

ខួរក្បាលទារកប្រៀបបាននឹងអេប៉ុង (ស្រូបទឹក) ដែលមានសមត្ថភាពស្រូបយក និងរៀនអ្វីៗដែលថ្មី។ នៅក្នុងរយៈពេលនៃឆ្នាំដំបូង កុមារស្តាប់ឮរៀនភាសាបានយ៉ាងលឿន។ នៅពេលដែលភាសា និងការប្រាស្រ័យទាក់ទងរបស់កុមារចេះតែអភិវឌ្ឍទៅមុខ លទ្ធភាពការគិតរបស់ពួកគេក៏លូតលាស់ទៅតាមនោះផងដែរ។ នេះជាហេតុផលសំខាន់ខ្លាំងណាស់ដែលឪពុកម្តាយត្រូវតែជួយកូនថ្លង់ ឬមិនអាចស្តាប់ឮល្អដើម្បីរៀនភាសាឱ្យទាន់ពេលអាចធ្វើបាន តាំងពីកុមារនៅអាយុតិចបំផុត។ ជាមួយភាសា កុមារមិនអាចស្តាប់ឮល្អអាចអភិវឌ្ឍគំនិតបញ្ញាបានផងដែរ។



## 14 កុមារមិនអាចស្តាប់ឮល្អ ត្រូវការជួយតាំងពីអាយុនៅតិច

# របៀបកុមារអភិវឌ្ឍបំណិនថ្មីៗ

កុមារអភិវឌ្ឍនៅក្នុងចំណុចចំបងៗចំនួន 4ផ្នែកមានៈ រាងកាយ (រូបរាង) ការគិត (គំនិតបញ្ញា) ការនិយាយនិងការស្តាប់ (ការប្រាស្រ័យទាក់ទង) ចេះសម្របខ្លួនជាមួយនឹងមនុស្សឯទៀត (សង្គម)។ នៅក្នុងផ្នែកនីមួយៗ កុមាររៀនបំណិនថ្មីមួយជំហានម្តងៗ។

ឧទាហរណ៏ មុនពេលក្មេងចេះដើរ ដំបូងក្មេងត្រូវតែរៀនបំណិនងាយៗជាច្រើននៃការទប់លំនឹងដងខ្លួន :-

**1. ដំបូង ក្មេងរៀនទប់លំនឹងក្បាល និងធ្វើចលនាកំរើកដៃជើង។**



**2. បន្ទាប់មក ក្មេងចេះប្រើដៃជើង ដើម្បីរៀនងើបអង្គុយ។**



**3. ក្នុងពេលចេះអង្គុយ ក្មេងអាចឈោង និងបង្វិលខ្លួន ជួយធ្វើឱ្យដំហរបានរឹងមាំឡើង។**



**4. ការចេះវារ ជួយក្មេងឱ្យចេះសម្របសម្រួលដៃជើង ក៏ដូចជាជួយអភិវឌ្ឍខួរក្បាលក្មេងផងដែរ។**



**5. បន្ទាប់មក ក្មេងចេះប្រឹងតោងឡើងដោយខ្លួនឯង ដើម្បីងើបឈរ។**



នៅគ្រប់ផ្នែកនៃការអភិវឌ្ឍបំណិនថ្មីនីមួយៗដែលក្មេងបានរៀន គឺបានជួយអភិវឌ្ឍទៅលើបំណិនដែលក្មេងចេះហើយ និងធ្វើឱ្យក្មេងមានលទ្ធភាពរៀនសូត្របំណិនពិបាកៗជាងនេះទៀត។

នៅពេលក្មេងមិនបានរៀនបំណិនមួយ ក្មេងមិនអាចរៀនបំណិនផ្សេងទៀត ដោយផ្អែកលើបំណិនដែលគេមិនបានរៀននោះទេ។ ឧទាហរណ៏ បើក្មេងមានបញ្ហាមិនអាចទប់លំនឹងក្បាល ក្មេងនឹងពិបាករៀនបំណិនដូចជារៀនវារ ឬអង្គុយ។ ប្រការចេះទប់លំនឹងក្បាលគឺជាការសំខាន់។




**បំណិនថ្មីនីមួយៗ បានអភិវឌ្ឍបន្តទៅលើបំណិនចេះហើយ ដូចសង់ដុំឈើត្រួតលើគ្នាអញ្ចឹងដែរ។**

## ការអភិវឌ្ឍជាដំណាក់ៗ
## នៃបំណិនប្រាស្រ័យទាក់ទង និងភាសារបស់កុមារ

ភាសារបស់កុមារបានអភិវឌ្ឍតាមវិធីដូចគ្នានឹងបំណិនកាយសម្បទាដែរ ។ ដំបូង ពួកគេរៀនបំណិនងាយៗ ។

**1. ទារកចាប់ផ្ដើមបង្ហាញគំនិត តម្រូវការ អារម្មណ៍របស់គេ ដោយបញ្ចេញសម្លេង ឬប្រើកាយវិការទឹកមុខ និងចង្អុល ។**




**2. ពួកគេស្ដាប់ឮ និងយល់ពាក្យមនុស្សទាំងឡាយនិយាយគ្នា ។**




**3. ពួកគេចាប់ផ្ដើមប្រើពាក្យ ។ ពួកគេស្គាល់ និងប្រើឈ្មោះរបស់មនុស្សដែលជិតដិតនឹងខ្លួន ។**




**4. ក្រោយមកពួកគេចាប់ផ្ដើមនិយាយ និងសំដែងអារម្មណ៍របស់ខ្លួនបានយ៉ាងពេញលេញ ។**




**5. ពាក្យសម្ដីជួយកុមារឱ្យចេះគិត និងរៀនអ្វីៗដែលថ្មី ។**




## ការរៀនសូត្រភាសា

ពេលមានពាក្យសម្ដីជាច្រើននៅព័ទ្ធជុំវិញអ្នក នោះជាការងាយស្រួលរៀនសូត្រភាសាដែលមនុស្សក្នុងសហគមន៍និយាយ ។ កុមាររៀនភាសាដោយស្ដាប់មនុស្សនិយាយគ្នាទៅវិញទៅមក និងចាំមើលអ្វីៗកើតឡើង និងពេលពួកគេនិយាយរកមនុស្សទាំងឡាយ ។ ភាសាក្លាយជាមធ្យោបាយមួយសំរាប់ជួយពួកគេឱ្យស្វែងយល់បទពិសោធន៍ និងការវិវឌ្ឍនៃព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញខ្លួនគេ ។

## 16 កុមារមិនអាចស្តាប់ឮល្អ ត្រូវការជួយតាំងពីអាយុនៅតិច

### រៀនភាសានិយាយ គឺជាការលំបាកសំរាប់កុមារមិនអាចស្តាប់ឮ




កាលណាកុមារមិនអាចស្តាប់ឮបានល្អ ពួកគេមានការលំបាកយល់ពាក្យនិយាយងាយៗយ៉ាងខ្លាំង។ កុមារត្រូវការចេះពាក្យសាមញ្ញជាច្រើន ដើម្បីរៀនភាសាមួយ។

ពេលពួកគេចេះពាក្យបានច្រើនហើយ កុមារអាចរៀនបំណិនប្រាស្រ័យទាក់ទងបានជ្រៅជាងនេះ ដូចជានិយាយជាឃ្លាល្បះនានា និងអាចជំរុញជាកិច្ចសន្ទនា។ កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អត្រូវការជំនួយដើម្បីរៀនបំណិនដូចជា និយាយពាក្យសាមញ្ញៗ ឬធ្វើអ្វីមួយដោយផ្អែកលើការប្រាស្រ័យទាក់ទងងាយៗ ដូចជាការផ្លាស់វេនគ្នា។



### កុមាររៀនភាសាជាជំហានៗ



បន្ទាប់មក ក្មេងអាចប្រើ**ភាសា**បាន**ពេញលេញ**ជាមួយសហគមន៍

**រៀន**ជាមួយពាក្យដែលបានប្រើ

**គិត**រកពាក្យប្រើឱ្យត្រឹមត្រូវ

**ប្រើ**ពាក្យ

**យល់** និងឆ្លើយតបទៅពាក្យដែលបានឮ

កុមារ**ស្តាប់ឮ**ពាក្យ



**ប៉ុន្តែបើគ្មានជំហានដំបូងនៃការស្តាប់ ឬការយល់...**



**....ក្មេងមិនអាចរៀនភាសា ដូច្នេះក្មេងមិនអាចអភិវឌ្ឍការគិត និងប្រាស្រ័យទាក់ទងបានទេ។**

**កុមារគ្មានមធ្យោបាយណានឹងក្លាយជាចំណែករបស់សហគមន៍បានឡើយ ហើយត្រូវបានបំភ្លេចចោល។**

## របៀបភាសាជួយអភិវឌ្ឍចិត្តគំនិត

ភាសាជួយកុមារឱ្យចេះគិត រៀបចំផែនការ យល់ដឹងនូវព្រឹត្តិការណ៍ទាំងឡាយជុំវិញខ្លួនគេ និងក្លាយជាចំណែកមួយនៃសហគមន៍។ **ចិត្តគំនិតរបស់កុមារមិនអាចអភិវឌ្ឍដោយគ្មានភាសាឡើយ។**

នៅពេលកុមារមិនអាចស្តាប់ឮ មិនបានទទួលជំនួយក្នុងការរៀនភាសាដើម្បីប្រាស្រ័យទាក់ទង ពួកគេប្រឈមមុខនឹងបញ្ហាអភិវឌ្ឍគំនិតបញ្ញា។ ឪពុកម្តាយភាគច្រើនដែលមានកូនតូចជាកុមារថ្លង់ ឬកុមារបានបាត់បង់ការស្តាប់ គឺពួកគាត់បានសប្បាយចិត្ត បើកូនបានចេះពាក្យងាយៗពីរបីពាក្យ ឬកាយវិការខ្លះៗ។ ប៉ុន្តែកុមារត្រូវការច្រើនជាងនេះ។ កុមារត្រូវការរៀនសូត្រភាសា។

កុមារថ្លង់ត្រូវការរៀនភាសាទាន់អាយុនៅតិច ធ្វើដូច្នេះកុមារអាចប្រើភាសាដើម្បី**និយាយរកខ្លួនឯង** ពោលគឺដើម្បី**គិត**។ ការបញ្ចេញគំនិតជាពាក្យនិយាយ ធ្វើឱ្យមានការត្រិះរិះអំពីគំនិតទាំងនោះ។




**ដោយសារ *អាមីណា*ស្គាល់ពាក្យសំរាប់ប្រៀបធៀប (ធំជាង និងតូចជាង)។ នាងមិនអាចសំដែងគំនិតជាពាក្យនិយាយបានឡើយ បើនាងមិនចេះពាក្យ (ធំជាង) នេះ។**




***វិស្សា*ចេះធ្វើផែនការ ដោយសារនាងចេះពាក្យតាមលំដាប់សំរាប់ធ្វើអ្វីៗ។**

កុមារក៏ត្រូវការភាសាដើម្បីបញ្ចេញគំនិតទៅឱ្យអ្នកឯទៀតដឹងផងដែរ ដើម្បីប្រាប់មនុស្សម្នានូវអ្វីដែលខ្លួនចង់បាន ឬត្រូវការ។ កុមារត្រូវការភាសាដើម្បីយល់នូវសេចក្តីពន្យល់ណែនាំនានា។ តាមរយៈការប្រាស្រ័យទាក់ទងជាមួយមនុស្សទាំងឡាយ កុមាររៀនសូត្រពីព្រឹត្តិការណ៍ជុំវិញខ្លួន។ ប្រការនេះជួយកុមារអភិវឌ្ឍចិត្តគំនិត និងធ្វើឱ្យកុមារបានផ្សារភ្ជាប់ទៅមនុស្សទាំងឡាយ។



**គ្មានភាសា កុមារប្រហែលជាមិនដឹងថា ហេតុអ្វីត្រូវនៅឱ្យឆ្ងាយពីគ្រោះថ្នាក់។ *ដន* មិនយល់ថា ហេតុអ្វីត្រូវបិទគំរបអណ្តូងទឹក។**




***អេវី*មិនយល់ហេតុផលដែលម្តាយនាងដឹងថា មានមនុស្សនៅឯមាត់ទ្វារ ដោយម្តាយនាងគ្មានវិធីណាអាចពន្យល់នាងបានឡើយ ។**

## កុមារថ្លង់ត្រូវការជួយតាំងពីអាយុនៅតិច




កុមារមិនអាចស្តាប់ឮអាចប្រាស្រ័យទាក់ទង និងរៀនភាសាបាន ដោយមានការជួយជ្រោមជ្រែង។ ទារកចាប់ផ្តើមរៀនតាំងពីកើតមកភ្លាម ជាការសំខាន់ដែលក្រុមគ្រួសារចាប់ផ្តើមផ្តល់ការយកចិត្តទុកដាក់ប្រាស្រ័យទាក់ទងបន្ថែម ដើម្បីជួយកូនថ្លង់ឱ្យទាន់ពេលដែលអាចធ្វើទៅបាន។

បើសិនជាកុមារមិនអាចស្តាប់ឮល្អបានទទួលការជួយជ្រោមជ្រែងរៀនភាសា ហើយភាសានោះជាភាសាសញ្ញា ពួកគេអាចយល់ និងអាចប្រាស្រ័យទាក់ទងជាមួយមនុស្សនៅជុំវិញខ្លួន។ បន្ទាប់មក ពួកគេអាចរៀនអ្វីៗដែលកុមារ ឯទៀតបានរៀនជាធម្មតា តាមរយៈការស្តាប់ឮ។




ឆ្នាំសិក្សាសំខាន់បំផុត (ពីថ្ងៃកើតដល់អាយុ7ឆ្នាំ) នឹងមិនបាត់បង់ បើសិនជាបញ្ហាការស្តាប់របស់កុមារត្រូវបានកត់សំគាល់ទាន់ពេល និងជួយយ៉ាងមានប្រសិទ្ធិភាព។ សូមអានជំពូកទី7 ទី8 និងទី9 សំរាប់ព័ត៌មានបន្ថែមអំពីការជួយកុមាររៀនភាសា។

## របៀបយល់ដឹង បើសិនជាកូនត្រូវការជំនួយ

ទារកអភិវឌ្ឍទៅតាមកំរិតរបស់ពួកគេ។ ទារកមួយចំនួនបានអភិវឌ្ឍលឿនជាងទារកមួយចំនួនទៀត។ ប៉ុន្តែកុមារស្ទើរតែទាំងអស់បានលូតលាស់ និងអភិវឌ្ឍបំណិនថ្មីៗនៅអាយុប្រហាក់ប្រហែលគ្នា។ ពេលអាយុបាន 2ឆ្នាំ កុមារស្ទើរតែទាំងអស់ចេះនិយាយ ឬចេះធ្វើសញ្ញាបានប្រមាណពី50 ទៅ 200ពាក្យ។ នៅអាយុ3ឆ្នាំ ជាធម្មតាកុមារម្នាក់ចេះបានប្រមាណ ៩00ពាក្យ និងចេះប្រមាណ 1500ពាក្យ នៅអាយុ 4ឆ្នាំ។

អ្វីដែលសំខាន់ គឺកុមាររៀនបំណិនថ្មីៗជាបន្តបន្ទាប់។ ប៉ុន្តែពេលក្មេងម្នាក់មិនបានរៀនបំណិនមួយ ទោះបីជាក្រោយពេលកុមារឯទៀតមានអាយុស្រករនឹងគេ បានរៀនបំណិននោះយូរហើយក៏ដោយ តាមធម្មតានេះគឺជាសញ្ញាសំគាល់មួយដែលបង្ហាញថា ក្មេងម្នាក់នេះមានបញ្ហា ឬត្រូវការជួយជ្រោមជ្រែងបន្ថែមទៀត។

តារាងនេះរៀបរាប់ខ្លះៗអំពីបំណិនប្រាស្រ័យមួយចំនួនដែលកុមារបានរៀន និងនៅពេលកុមារស្ទើរតែទាំងអស់រៀនបំណិនទាំងនោះ។ ឪពុកម្តាយអាចប្រើតារាងដើម្បីសំរេចថា បំណិនណាខ្លះដែលកូនចេះហើយ និងបំណិនណាខ្លះដែលកូនត្រូវរៀន។ ដើម្បីកំណត់ថា ត្រូវធ្វើសកម្មភាពអ្វីមុន គួរផ្តើមសួរខ្លួនឯងថា "តើកូនខ្ញុំកំពុងធ្វើអ្វីៗដែលកុមារស្រករៗគ្នាផ្សេងទៀតកំពុងធ្វើឬទេ? សំរាប់ព័ត៌មានបន្ថែមស្តីពីអាយុ និងលំដាប់លំដោយនៃបំណិនថ្មីៗដែលកុមាររៀនតាមធម្មតា សូមអានតារាងអភិវឌ្ឍកុមារ នៅទំព័រ231 ដល់ 238។



**3ខែ**

- ឆ្លើយតបទៅសម្លេងធ្លាប់ឮ និងមុខធ្លាប់ឃើញ
- មានប្រតិកម្មចំពោះសម្លេង ឬចលនាបន្ទាន់ភ្លាមៗ



**6ខែ**

- ធ្វើសម្លេងងាយៗ និងកាយវិការ
- ងាកក្បាលទៅរកចលនា និងសម្លេង



**1 ឆ្នាំ**

- យល់ និងឆ្លើយតបចំពោះពាក្យ ឬសញ្ញាងាយៗ។
- ភ្ជាប់សម្លេងជាមួយគ្នា ឬធ្វើទ្រង់ទ្រាយដៃដដែលៗ។
- ធ្វើត្រាប់តាមសញ្ញាទោល។
- ចាប់ផ្តើមដាក់ឈ្មោះឱ្យវត្ថុ។




**2ឆ្នាំ**

- ប្រើពាក្យ ឬ សញ្ញាងាយៗ។ ប្រើឃ្លាដែលមានពាក្យ ឬសញ្ញាពីរបីម៉ាត់។
- ស្គាល់ប្រមាណពី50 ទៅ 200ពាក្យ ឬសញ្ញា។




**3ឆ្នាំ**

- យល់ភាសាសាមញ្ញស្ទើរតែទាំងអស់។
- ស្គាល់ និងចេះប្រើពាក្យប្រមាណពី500 ទៅ 1000ពាក្យ ឬសញ្ញា។




**5ឆ្នាំ**

- និយាយ ឬធ្វើសញ្ញាអំពីអ្វីដែលខ្លួនបានធ្វើ
- សួរសំណួរជាច្រើន។




***សំគាល់:*** កុមារមិនអាចស្តាប់ឮល្អមួយចំនួន អាចនឹងមានបញ្ហាផ្សេងៗ។ ចិត្ត គំនិត និងរាងកាយរបស់ពួកគេអាចលូតលាស់យឺតដោយសារហេតុផលផ្សេងៗទៀត។ សូមអានសៀវភៅឈ្មោះ **"កុមារពិការក្នុងភូមិ" "Disabled Village Children"** សំរាប់ព័ត៌មានបន្ថែម ស្តីពីរបៀបជួយកុមារលូតលាស់យឺតផ្នែកចិត្ត គំនិត ឬរាងកាយ។

## អ្នកអាចជួយកូនឱ្យរៀនសូត្រ

អ្នកអាចជួយបង្រៀនកូន បើសិនជាអ្នកគិតថា ការប្រាស្រ័យទាក់ទងរបស់កូនមិនបានអភិវឌ្ឍទៅតាមកំរិត។ ជាញឹកញាប់ឪពុកម្តាយតែងគិតថា ទាល់តែអ្នកមានជំនាញពិសេសទើបអាចជួយកូនគាត់បាន។ ក្នុងនាមជាឪពុកម្តាយ អ្នកស្គាល់កូនច្បាស់ជាងគេទាំងអស់ ដូច្នេះអ្នកអាចធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងការអភិវឌ្ឍរបស់កូន។




**ជំពូកទី3 ដល់ទី9 អ្នកអាចរកឃើញព័ត៌មានអំពី :-**

- គោលការណ៍ណែនាំសំរាប់ការបង្រៀនភាសា (ជំពូកទី3)
- មូលដ្ឋាននៃបំណិនការប្រាស្រ័យទាក់ទង (ជំពូកទី4)
- ការស្វែងរកឱ្យឃើញនូវអ្វីដែលកូនអាចស្តាប់ឮ (ជំពូកទី5)
- បំណិនស្តាប់ (ជំពូកទី6)
- ការជ្រើសរើស និងការរៀនភាសា (ជំពូកទី7)
- ការរៀនភាសាសញ្ញា (ជំពូកទី8)
- ការរៀនភាសានិយាយ (ជំពូកទី9)

